# ជីវប្រវត្តរបស់អ៊ីម៉ាំ អាល់-ហាសាន់ صلوات الله عليه والسلام



សៃយីដ្ធ ម៉ាស្វឌ្ធី អាយ៉ាទុលឡ៍ហ៊ី

ស្ហាគីប បេនបេឌីរ៉ា

بسم الله الرحمن الرحيم



## ពាក្យពេចន៍ត្រចះត្រចង់របស់អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام

-មិនស្គាល់ធម៌មេត្តាជាសេចក្ដីថោកទាប ។

-រាល់ពេលដែលមនុស្សមួយក្រុមពិភាក្សាគ្នា ត្រូវតែគិតឲ្យសព្វគ្រប់ជាចាំបាច់ ។

-អាម៉ាស់មុខប្រសើរជាងភ្លើងនរក ។

-មនុស្សជំនិតគឺមនុស្សដែលមិត្តភាពនាំមកជិត ថ្វីដ្បិតតែមានសាលោហិតឆ្ងាយ ។ មនុស្សសាច់ឆ្ងាយគឺមនុស្សដែលមិត្តភាពធ្វើឲ្យឃ្លាតឆ្ងាយ ថ្វីដ្បិតតែមានសាលោហិតជិត ។



# បញ្ជីមាតិកា


កំណើត ........................................ 4

ឫកសុភាពរបស់អ៊ីម៉ាំ صلوات الله عليه والسلام ........................................ 5

ព្រះអង្គ صلوات الله عليه والسلام មានសទ្ធាជ្រះថ្លា ........................................ 6

ព្រះអង្គ صلوات الله عليه والسلام មានការអត់ឱន ........................................ 8

ព្រះអង្គ صلوات الله عليه والسلام មានព្រះហឫទ័យទូលំទូលាយ ........................................ 10

អ៊ីម៉ាំ صلوات الله عليه والسلام និងអំណាច ........................................ 11

មូអាវីយ៉ាសុំរៀបផែនការក្បត់ ........................................ 14

ការប្រុងប្រៀបធ្វើសង្គ្រាម ........................................ 15

សន្តិភាព ........................................ 22

មូអាវីយ៉ាសុំក្បត់សន្ធិសញ្ញាសន្តិភាព ........................................ 25

ការធ្វើគុតអ៊ីម៉ាំអាល់-ហ្ហាសាន់ صلوات الله عليه والسلام ........................................ 27

អត្តសញ្ញាណ ........................................ 29

ពាក្យពេចន៍ត្រចះត្រចង់របស់អ៊ីម៉ាំអាល់-ហ្ហាសាន់ صلوات الله عليه والسلام ........................................ 31

# កំណើត

អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ប្រសូតថ្ងៃទី ១៥ ខែរ៉ម៉ាដូនឆ្នាំទី ៣ សកករាជហ៊ីជ្រ៉េះត្ទ័ ។ ព្រះអង្គ صلوات الله عليه والسلام បានប្រសូតនៅក្នុងគេហដ្ឋានមួយដែលធ្វើអំពីដីឥដ្ឋ តែបរិយាកាសនៅក្នុងគេហដ្ឋាននោះពិសេសបំផុត ។

មែន ព្រះអយ្យកោ صلى الله عليه وآله وسلم ព្រះអង្គ صلوات الله عليه والسلام គឺព្រះសាស្ដា صلى الله عليه وآله وسلم របស់អល់ឡោះហ៊ូ عز وجل ដែលផ្ដួចផ្ដើមអប់រំព្រះអង្គ صلوات الله عليه والسلام ដោយសេចក្ដីស្រឡាញ់ ។ ព្រះបិតាព្រះអង្គ صلوات الله عليه والسلام គឺអ៊ាលី صلوات الله عليه والسلام ប៊ិន អាប៊ូ ត្ទ៉លិប ។ ព្រះមាតាព្រះអង្គ صلوات الله عليه والسلام គឺហ្វាទីម៉ាស្ហ៍ سلام الله عليها ។ ព្រះអង្គ صلوات الله عليه والسلام នៅក្នុងគ្រួសារសុក្រឹតនិងបរិសុទ្ធ ។

ព្រះសាស្ដា صلى الله عليه وآله وسلم តែងតែមានព្រះវចនៈថា អាល់-ហាសាន់ صلوات الله عليه والسلام ជាព្រះរាជបុត្ររបស់ព្រះអង្គ صلى الله عليه وآله وسلم ហើយព្រះអង្គ صلوات الله عليه والسلام ជាផ្កាដែលមានគន្ធពិដោររបស់ព្រះអង្គ صلى الله عليه وآله وسلم ក្នុងលោកនេះ ។ មុស្លីមទាំងឡាយបានឃើញអាល់-ហាសាន់ صلوات الله عليه والسلام ជិះកព្រះអង្គ صلى الله عليه وآله وسلم ជាច្រើនលើកច្រើនគ្រា ដោយមានព្រះវចនៈថា៖

«រាជបុត្រខ្ញុំនេះជាព្រះរាជអគ្គមហាប្រមុខ ។ ប្រហែលជាអល់ឡោះហ៊ូ عز وجل អាចឲ្យគេផ្សះផ្សាមុស្លីមពីរក្រុមបាន ។»

បន្ទាប់មកព្រះអង្គ صلى الله عليه وآله وسلم បានបួងសួងអល់ឡោះហ៊ូ عز وجل ថា៖



គេបានបញ្ចុះព្រះរាជសពព្រះអង្គ صلوات الله عليه والسلام នៅឯសុសានអាល់-បាគីអ៊ (البقيع) ក្បែរម៉ាឌីណាស្ហ៍ ។ សូមឲ្យសិរីសួស្ដីកើតមានដល់ព្រះអង្គ صلوات الله عليه والسلام ថ្ងៃដែលព្រះអង្គ صلوات الله عليه والسلام បានប្រសូតមក ថ្ងៃដែលព្រះអង្គ صلوات الله عليه والسلام បានចូលទិវង្គត ថ្ងៃដែលព្រះអង្គ صلوات الله عليه والسلام នឹងរស់ឡើងវិញ ។

# អត្តសញ្ញាណ

ត្រកូលនិងព្រះនាម៖ អាល់-ហាសាន់ អាល់-មុជ្តាបា ។

ព្រះនាមតម្កើង៖ អាប៊ូ មូហាំម៉ាដ់ صلوات الله عليه والسلام ។

ព្រះនាមព្រះបិតា៖ អ៊ាលី صلوات الله عليه والسلام ។

ព្រះនាមព្រះមាតា៖ ហ្វាទីម៉ាស្ហ៍ سلام الله عليها ។

ព្រះនាមព្រះអយ្យកោ៖ មូហាំម៉ាដ់ صلى الله عليه وآله وسلم ។

ថ្ងៃកំណើត៖ ថ្ងៃទី ១៥ ខែរ៉ម៉ាដូនឆ្នាំទី ៣ សកករាជហ៊ីជ្រ៉េះត្ទ័ ។

ព្រះជន្មពេលចូលទិវង្គត៖ ៤៧ ព្រះវស្សា ។

ថ្ងៃធ្វើទុក្ករកម្ម៖ ថ្ងៃទី ២៨ ខែស្វ៉ហ្វារ ឆ្នាំទី ៥០ សកករាជហ៊ីជ្រ៉េះត្ទ័ ។

ព្រះមហេសីរបស់ក្សត្រដែលនឹងស្នងរាជ្យ គឺយ៉ាស៊ីដ នៅពេលអនាគត ។ យ៉ាក់ដាស្ទ់យល់ព្រម ។ មូអាវីយ៉ាស្ទ់បានឲ្យថ្នាំបំពុលមកយ៉ាក់ដាស្ទ់ ។ យ៉ាក់ដាស្ទ់បានដាក់ថ្នាំបំពុលក្នុងចំណីរបស់អ៊ីមុាំ صلوات الله عليه والسلام ពេលព្រះអង្គ صلوات الله عليه والسلام ស្រាយត្រណមអត់អាហារ ។ ព្រះអង្គ صلوات الله عليه والسلام ឈឺខ្លាំងណាស់ ។ ព្រះអង្គ صلوات الله عليه والسلام យល់ភ្លាមថាព្រះអង្គ صلوات الله عليه والسلام ត្រូវមហេសីព្រះអង្គ صلوات الله عليه والسلام ដាក់ថ្នាំបំពុល ។ ព្រះអង្គ صلوات الله عليه والسلام បានប្រាប់នាងថា៖ “សត្រូវអល់ឡោះហ៊ូ عز وجل ! នាងឯងសម្លាប់យើង ។ សូមឲ្យអល់ឡោះហ៊ូ عز وجل សម្លាប់នាងឯង ! មូអាវីយ៉ាស្ទ់បានបោកប្រាស់នាងឯងហើយ ។ មូអាវីយ៉ាស្ទ់បានចំអកឲ្យនាងឯង ! សូមឲ្យអល់ឡោះហ៊ូ عز وجل បំបាក់មុខពួកឯងទាំងពីរ មូអាវីយ៉ាស្ទ់និងនាងឯង !”

លុះយ៉ាក់ដាស្ទ់បានទៅជួបមូអាវីយ៉ាស្ទ់ដើម្បីទាមទាររង្វាន់ មូអាវីយ៉ាស្ទ់បានដេញនាងត្រឡប់វិញដោយប្រមាថថា៖ “យើងចង់ឲ្យយ៉ាស៊ីដរស់រានមានជីវិត !” ហើយបានបណ្ដេញនាងចេញពីវិមានខ្លួន ។

ថ្ងៃទី ២៨ ខែស្ហ៉ហ្វារ ឆ្នាំទី ៥០ សករាជហ៊ិជ្ជរ៉ោះត្ទ័ វិញ្ញាណអ៊ីមុាំអាល់-ហ្សាសាន់ صلوات الله عليه والسلام បានឡើងទៅឯព្រះម្ចាស់ عز وجل ព្រះអង្គ صلوات الله عليه والسلام ប្ដឹងអល់ឡោះហ៊ូ عز وجل ពីអំពើអយុត្តិធម៌របស់ពួកអ៊ូម៉ៃយ៉ាស្ទ់ ។



«អល់ឡោះហ៊ូ عز وجل អើយ សូមព្រះអង្គ عز وجل ស្រឡាញ់គេ صلوات الله عليه والسلام និងស្រឡាញ់អ្នកណាដែលស្រឡាញ់គេ صلوات الله عليه والسلام ។»

ព្រះសាស្ដា صلى الله عليه وآله وسلم ធ្លាប់មានព្រះវចនៈច្រើនលើកច្រើនគ្រាដែរថា៖ «អាល់-ហ្សាសាន់ صلوات الله عليه والسلام និងអាល់-ហ៊្សូសែន صلوات الله عليه والسلام ជាព្រះរាជអគ្គមហាប្រមុខរបស់បណ្ដាយុវជនឋានសួគ៌ ។»

គ្រាមួយ ព្រះសាស្ដា صلى الله عليه وآله وسلم កំពុងតែក្រាបប្រណិប័តន៍ អាល់-ហ្សាសាន់ صلوات الله عليه والسلام បានឡើងជិះកព្រះអង្គ صلى الله عليه وآله وسلم ។ ព្រះអង្គ صلى الله عليه وآله وسلم កម្រើកព្រះសិរតិចៗព្រោះខ្លាចព្រះអង្គ صلوات الله عليه والسلام ធ្លាក់ ។

បានឃើញព្រឹត្តិការណ៍ចម្លែកនេះ សាវកទាំងឡាយក៏បានទូលព្រះអង្គ صلى الله عليه وآله وسلم ថា៖ «អស់ទូលបង្គំបានឃើញថាព្រះអង្គ صلى الله عليه وآله وسلم មិនដែលប្រព្រឹត្តបែបនេះចំពោះអ្នកណាផ្សេងក្រៅពីក្មេងនេះទេ ។» ព្រះសាស្ដា صلى الله عليه وآله وسلم មានព្រះវចនៈថា៖ «ក្មេង صلوات الله عليه والسلام នេះជាផ្កាដែលមានក្លិនក្រអូបរបស់ខ្ញុំ صلى الله عليه وآله وسلم ។ កូន صلوات الله عليه والسلام ខ្ញុំនេះជាព្រះបរមគ្រូមួយរូប ។ ខ្ញុំសង្ឃឹមថាអល់ឡោះហ៊ូនឹងធ្វើឲ្យមុស្លីមពីរក្រុមស្រុះស្រួលគ្នាដោយសារគេ صلوات الله عليه والسلام ។»

## ឫកសុភាពរបស់អ៊ីមុាំ صلوات الله عليه والسلام

អាល់-ហាសាន់ صلوات الله عليه والسلام និងអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام បានទៅម៉ាស់យ៊ីដ ។ ព្រះអង្គ عليهم السلام ទាំងពីរបានឃើញបុរសវ័យចំណាស់ម្នាក់ យកទឹកស៊ូឡាត់ខុសបន្តិចបន្តួច ។ អ៊ីមុាំអាល់-ហាសាន់ صلوات الله عليه والسلام រិះរកមធ្យោបាយកែខៃវិធីយកទឹកស៊ូឡាត់របស់បុរសចំណាស់រូបនេះ ដោយមិនចង់ឲ្យគាត់យល់ច្រឡំផងដែរថាវាជាទង្វើមិនគប្បីមកលើគាត់ ។ អាល់-ហាសាន់ صلوات الله عليه والسلام និងអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام បានចូលទៅជិតបុរសចំណាស់ ធ្វើជាមិនចុះសម្រុងគ្នាអំពីរបៀបយកទឹកស៊ូឡាត់ សូមឲ្យគាត់ជួយធ្វើអាជ្ញាកណ្តាល ។ អាល់-ហាសាន់ صلوات الله عليه والسلام និងអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام បាននិយាយរកគ្នាថា៖ «អូនឯងមិនចេះយកទឹកស៊ូឡាត់ទេ !» ព្រះអង្គទាំងពីរបានយកទឹកស៊ូឡាត់នៅចំពោះមុខបុរសចំណាស់ៗ ក៏បានដឹងកំហុសខ្លួន ហើយបានយល់ន័យទង្វើរបស់ព្រះអង្គ عليهم السلام ទាំងពីរ ។ គាត់បានទូលព្រះអង្គ عليهم السلام ទាំងពីរ ទាំងញញឹម ថា៖ «ព្រះអង្គ عليهم السلام ទាំងពីរចេះយកទឹកស៊ូឡាត់យ៉ាងត្រឹមត្រូវ ។» ព្រមនឹងចង្អុលខ្លួនឯងផង គាត់បានទូលថា៖ «បុរសចំណាស់រូបនេះទេដែលមិនចេះយកទឹកស៊ូឡាត់នោះ ។ បុរសចំណាស់រូបនេះទើបនឹងបានចេះយកទឹកស៊ូឡាត់ពីព្រះអង្គ عليهم السلام ទាំងពីរ !»

## ព្រះអង្គ صلوات الله عليه والسلام មានសទ្ធាជ្រះថ្លា



នេះ ។ មូអាវីយ៉ាស់សម្រេចចិត្តកម្ចាត់ព្រះអង្គ صلوات الله عليه والسلام ចោល ។

## ការធ្វើគុតអ៊ីមុាំអាល់-ហាសាន់ صلوات الله عليه والسلام

មូអាវីយ៉ាស់ដឹងច្បាស់ថា ការបន្តរឈោមអ៊ីមុាំអាល់-ហាសាន់ صلوات الله عليه والسلام ប្រាកដជានឹងធ្វើឲ្យប្រជារាស្ត្រមានប្រតិកម្ម និងធ្វើឲ្យអំណាចខ្លួននោះមានការជ្រួលច្របល់ ។ ដូច្នេះហើយបានជាមូអាវីយ៉ាស់ជ្រើសយកវិធីសម្លាប់អ៊ីមុាំ صلوات الله عليه والسلام ដោយដាក់ថ្នាំបំពុល ។ មូអាវីយ៉ាស់បានប្រើវិធីនេះដែរដើម្បីសម្លាប់បុគ្គលល្បីៗដូចជាម៉ាលិក អាល់-អាស្ទ៍តារ អគិបាលប្រទេសអេស៊ីបត៍តែងតាំងដោយអ៊ីមុាំអាលី صلوات الله عليه والسلام ។

ដើម្បីអនុវត្តិតាមផែនការអាក្រក់នេះ មូអាវីយ៉ាស់មិនមានបុគ្គលដែដល់ណាក្រៅពីយ៉ាក់ដាស់ ប៊ិនទី អាល់-អាស់អាស់ (جعدة بنت الأشعث) ទេ ។ ឪពុករបស់យ៉ាក់ដាស់ជាបុគ្គលលាក់ពុតត្បុត ដែលបានសម្តែងការគាំទ្រអ៊ីមុាំអាលី صلوات الله عليه والسلام ។ យ៉ាក់ដាស់ជាមហេសីរបស់អ៊ីមុាំអាល់-ហាសាន់ صلوات الله عليه والسلام តែគាត់ទៅរកឪពុក ។ មូអាវីយ៉ាស់ស្គាល់រឿងនេះច្បាស់ណាស់ ហើយបានស្នើផ្តល់នូវអ្វីមួយដែលទាក់ចិត្តអនេកគឺ៖ ប្រសិនបើនាងសម្លាប់ស្វាមីនាងៗនឹងក្លាយទៅជា

កាន់សីលតមអាហារនោះទេ ។ តែដើម្បីខ្ញុំនឹងគ្រប់គ្រងអស់លោកនោះវិញទេ… លក្ខខណ្ឌទាំងអស់ដែលខ្ញុំបានចុះហត្ថលេខាឲ្យអាល់-ហាសាន់ صلوات الله عليه والسلام នោះនៅក្រោមបាតជើងខ្ញុំចាប់ពីពេលនេះតទៅ ។”

មូអ៊ាវីយ៉ាស់បានជ្រើសរើស “ស៊ីយ៉ាដ់ អ៊ីបនូ អាប៊ូ” ដែលជាកូនឥតខាន់ស្លារបស់អាប៊ូ ស៊ុហ្វយ៉ាន ជាអភិបាលស្រុកគូហ្វាស់ ។ បុរសកំណាចនិងប្រែកបដោយគ្រោះថ្នាក់រូបនេះឃោរឃៅបំផុត ។ គាត់ព្យាយាមសម្លាប់អ្នកស្រឡាញ់អាស់លុលបៃត៍ عليهم السلام (ពួកស៊ីអាស់) ដែលបានរងទុក្ខវេទនាដ៏ធំ ។

ប្រឈមនឹងស្ថានភាពអាក្រក់នេះ អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام បានជួយសង្គ្រោះបណ្ដាអ្នកស្វាមីភក្ដិរបស់ព្រះអង្គ صلوات الله عليه والسلام ឥតសំចៃកម្លាំងឡើយ ថ្វីដ្បិតតែព្រះអង្គ صلوات الله عليه والسلام នៅក្រោមការឡោមព័ទ្ធ ។

មហាជនកាន់តែគាំទ្រការកាត់ទោសមូអ៊ាវីយ៉ាស់ ដោយអ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ។ មូអ៊ាវីយ៉ាស់កាន់តែទើសទាល់ទៅៗ ជាពិសេសពេលសម្រេចចិត្តតែងតាំងកូនរបស់ខ្លួនឈ្មោះយ៉ាស៊ីដជាក្សត្រស្នងរាជ្យ និងលុបចោលរបបខ៊ិលីហ្វាស់ក្នុងឱកាសតែមួយនេះ ដើម្បីបង្កើតឡើងនូវរាជានិយមនិងរាជាធិបតេយ្យផ្ដាច់ការ ។

អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ជាឧបសគ្គធំពាំងពីមុខផែនការអាក្រក់ទាំង



គេស្គាល់អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ព្រោះព្រះអង្គ صلوات الله عليه والسلام ជាបុគ្គលដែលមានសទ្ធាស៊ប់ចិត្តបំផុត ។ ព្រះអង្គ صلوات الله عليه والسلام មានកេរ្តិ៍ឈ្មោះជាបុគ្គលដែលគោរពបូជាអល់ឡោះហ៊ុ عز وجل ជាទីបំផុតនាសម័យព្រះអង្គ صلوات الله عليه والسلام ។ ព្រះអង្គ صلوات الله عليه والسلام បានទៅបំពេញពិធីបូជនីយសក់(ពិធីហាជ្ជ) ២៥ ដងដោយថ្មើរជើងពីម៉ាឌីណាស់ទៅម៉ាក់កាស់ ។

រាល់គ្រាដែលព្រះអង្គ صلوات الله عليه والسلام ក្រោកធ្វើសក្ការៈបូជាអល់ឡោះហ៊ុ عز وجل ព្រះអង្គ صلوات الله عليه والسلام ឡើងសម្បុរលឿង ហើយញ័រខ្លួនចំប្រប់ព្រោះតែខ្លាចអល់ឡោះហ៊ុ عز وجل ។ ព្រះអង្គ صلوات الله عليه والسلام មានវចនៈថា៖ “អ្នកណាក៏ដោយដែលបង្ហាញខ្លួនចំពោះអល់ឡោះហ៊ុ عز وجل អ្នកនោះត្រូវតែឡើងសម្បុរលឿងនិងញ័រខ្លួនចំប្រប់ ។”

ពេលមកដល់មាត់ទ្វារម៉ាស់យ៊ីដ ព្រះអង្គ صلوات الله عليه والسلام ងើយព្រះសិរឡើង ហើយទូលថា៖ “អល់ឡោះហ៊ុ عز وجل អើយ ភ្ញៀវព្រះអង្គ عز وجل មកដល់ហើយ ឱព្រះដ៏មានព្រះសប្បុរសធម៌អើយ ។ បុគ្គលល្មើសច្បាប់មកដល់ព្រះមហាគ្រឹះព្រះអង្គ عز وجل ហើយ ។ ឱព្រះដ៏មានព្រះហឫទ័យទូលំទូលាយអើយ សូមព្រះអង្គ عز وجل រំលងនិងកុំយកព្រះហឫទ័យទុកដាក់នឹងសេចក្ដីអាក្រក់ ដែលទូលព្រះបង្គំជាខ្ញុំមាននោះឡើយ អាស្រ័យសេចក្ដីល្អប្រសើរដែលនៅឯព្រះអង្គ عز وجل ។”

# ព្រះអង្គ صلوات الله عليه والسلام មានការអត់ឱន

ថ្ងៃមួយ នៅតាមផ្លូវ ព្រះអង្គ صلوات الله عليه والسلام បានជួបបុរសជាតិស៊ីរីម្នាក់ដែលល្បីថា ស្អប់ខ្ពើមអាស្ហុលុល-បៃត៍ عليهم السلام ណាស់ ។ បុរសស៊ីរីបានជេរប្រទេចអ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ឥតសំចៃមាត់ឡើយ ដោយព្យាយាមបង្កជម្លោះ ។ តែអ៊ីម៉ាំ صلوات الله عليه والسلام នៅស្ងៀមស្ងាត់ ចាំឲ្យបុរសរូបនេះពោលផរុសវាចាចប់ ។ បន្ទាប់ពីនោះ ព្រះអង្គ صلوات الله عليه والسلام បានគំនាប់គាត់ដោយញញឹម ហើយមានវចនៈថា៖ “លោកមិនមែនអ្នកស្រុកនេះទេ មែនទេ? បើលោកចង់បានអ្វីយើងនឹងឲ្យលោក! បើលោកចង់សួរអ្វីយើង យើងនឹងប្រាប់លោក! បើលោកឃ្លានយើងនឹងឲ្យលោកបរិភោគលុះឆ្អែត! បើលោកពុំមានសំលៀកបំពាក់សមគួរទេ យើងនឹងផ្តល់សំលៀកបំពាក់សមគួរឲ្យលោក! បើលោកក្រ យើងនឹងឲ្យលោកមានបាន ។ ប្រសិនបើគេតាមចាប់លោក យើងនឹងឲ្យជម្រកលោក ។ បើលោកមានបញ្ហា យើងនឹងជួយដោះស្រាយឲ្យលោក!”

សីលធម៌ឧត្តុង្គឧត្តមនេះធ្វើឲ្យបុរសស៊ីរីស្រឡាំងកាំង ។ គាត់ទើបនឹងដឹងថា មូអាវីយ៉ាស្ហ់ អភិបាលប្រទេសស៊ីរី បោកប្រាស់គេ បំភ្លៃការពិត និងនិយាយបង្ខូចឈ្មោះអ៊ីម៉ាំ صلوات الله عليه والسلام និងរាជបុត្រ عليهم السلام ព្រះអង្គ صلوات الله عليه والسلام ។



# មូអាវីយ៉ាស្ហ់ក្បត់សន្ធិសញ្ញាសន្តិភាព

អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ដឹងច្បាស់ថា មូអាវីយ៉ាស្ហ់នឹងមិនគោរពពាក្យសន្យាទេ ។ តែព្រះអង្គ صلوات الله عليه والسلام ចង់វែកមុខបុគ្គលបះបោរលោភអំណាចរូបនេះឲ្យសហគមន៍មុស្លីមឃើញ ។ ក្នុងពេលតែមួយនេះដែរ ព្រះអង្គ صلوات الله عليه والسلام មានបំណងលះបង់ខ្លួនដើម្បីបំពេញបេសកកម្ម ដែលព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام បានបំពេញបន្ទាប់ពីព្រះសាស្តា صلى الله عليه وآله وسلم បានចូលទិវង្គតទៅនោះគឺ៖ បង្ហាត់បង្រៀនអ៊ីស្លាមបរិសុទ្ធ និងត្រឹមត្រូវដល់មនុស្សទាំងឡាយដែលទើបនឹងមកកាន់សាសនា និងថែរក្សាការពារជំនឿបរិសុទ្ធចំពោះព្រះតែមួយគត់ឲ្យបានផុតពីការកាឡៃក្លែងក្លាយសព្វបែបយ៉ាង ។

មិនយូរប៉ុន្មានមូអាវីយ៉ាស្ហ់បានចោលរបាំងមុខ បើកឲ្យឃើញមុខពិតរបស់ខ្លួន គឺមុខបុគ្គលលាក់ពុតត្បុតដែលមិនដែលជឿសាសនាអ៊ីស្លាមសោះឡើយ និងមិនដែលជឿសាសនាឬលិទ្ធិណាផ្សេងឡើយ ក្រៅពីស្រឡាញ់អំណាចនោះ ។ មែនហើយ ចាប់តាំងពីបានចូលមកកាន់គូហ្វាស្ហ់ភ្លាម បន្ទាប់ពីបានចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិសុខ មូអាវីយ៉ាស្ហ់បានធ្វើសុន្ទរកថាក្រអឺតមួយថា៖ “ខ្ញុំមិនដែលប្រយុទ្ធទល់អស់លោកដើម្បីអស់លោកនឹងឲ្យធ្វើនមស្ការនិង







បុរសស៊ីរីរំភើបពេកក៏បានយំ ហើយទូលថា៖ «ទូលនង្គំសូមប្ដេជ្ញាថាព្រះអង្គ صلوات الله عليه والسلام ជាអ្នកជំនួយការរបស់អល់ឡោះហ៍ عز وجل នៅលើផែនដីនេះ ថាអល់ឡោះហ៍ عز وجل ចេះទុកដាក់ព្រះបន្ទូលរបស់ព្រះអង្គ عز وجل ណាស់ ។ កាលពីមុនព្រះអង្គ صلوات الله عليه والسلام និងព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام ជាបុគ្គលដែលគួរឲ្យស្អប់បំផុត តែឥឡូវនេះព្រះអង្គ صلوات الله عليه والسلام ជាបុគ្គលជាទីគោរពនិងជាទីស្រឡាញ់បំផុតសម្រាប់ទូលព្រះបង្គំ លើសអស់ទាំងសត្វលោក ។» បន្ទាប់មក បុរសស៊ីរីបានស្នាក់នៅឯដំណាក់អ៊ីម៉ាំ صلوات الله عليه والسلام តាមការអញ្ជើញរបស់ព្រះអង្គ صلوات الله عليه والسلام ។

## ព្រះអង្គ صلوات الله عليه والسلام មានព្រះហឫទ័យទូលំទូលាយ

បុរសម្នាក់បានសូមជំនួយពីអ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ។ គាត់បានទទួលនូវលទ្ធភាពដែលអាចធ្វើឲ្យគាត់រស់នៅបាន ដោយមិនបាច់ពឹងពាក់គេ ។

ថ្ងៃមួយបុរសចរកជនបានមកសូមជំនួយពីអ៊ីម៉ាំ صلوات الله عليه والسلام ។ ព្រះអង្គ صلوات الله عليه والسلام មានព្រះវចនៈថា៖ «អ្វីៗដែលមាននៅក្នុងទូឲ្យទៅគាត់ទាំងអស់ !»

ថ្ងៃមួយ អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام កំពុងតែធ្វើពិធីដើរថ្វៃលកាក់បាស្ទ៍ ព្រះអង្គ صلوات الله عليه والسلام បានឮបុរសម្នាក់អង្វរបួងសួងអល់ឡោះហ៍ عز وجل សូមឲ្យព្រះអង្គ عز وجل



លើក្រដាសនោះ ។ អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ដឹងច្បាស់ថានេះគ្រាន់តែជាល្បិចរបស់សត្វកញ្ជ្រោងស្រែកឃ្លានអំណាចប៉ុណ្ណោះ ។ ព្រះអង្គ صلوات الله عليه والسلام ដឹងដែរថាព្រះអង្គ صلوات الله عليه والسلام មិនមានជម្រើសទេ ហើយព្រះអង្គ صلوات الله عليه والسلام ក៏អស់ពាក្យសំអាងដើម្បីលើកយកមកបង្ហាញបណ្ដាមុស្លីម ដើម្បីបន្តការកាន់អាវុធតស៊ូតទៅទៀតដែរ ។ ព្រះអង្គ صلوات الله عليه والسلام បានចុះលក្ខខណ្ឌថា៖

១.មូអាវីយ៉ាស្ទ៍ត្រូវតែគ្រប់គ្រងតាមព្រះគម្ពីរគួរអាននិងតាមទំនៀមរបស់ព្រះសាស្ដា صلى الله عليه وآله وسلم ។

២.មូអាវីយ៉ាស្ទ៍ត្រូវតែមិនរំខានបណ្ដាអ្នកប្រតិបត្តិតាមអាស្ទ៍លុលបៃត៍ ។

៣.មូអាវីយ៉ាស្ទ៍ត្រូវតែហាមឃាត់ការជេរតិះដៀលទាំងអស់ ឬការនិយាយបង្ខូចកេរ្ដិ៍ឈ្មោះទៅលើរូបអាលី صلوات الله عليه والسلام ។

៤.មូអាវីយ៉ាស្ទ៍មិនមានសិទ្ធិជ្រើសរើសអ្នកណាម្នាក់ ឡើងកាន់ខ៊ីលីហ្វាស្ទ៍ទេ ។

៥.អាល់-ហាសាន់ صلوات الله عليه والسلام មានសិទ្ធិមិនហៅមូអាវីយ៉ាស្ទ៍បានថា "អាមីរុល-មុមីនីន" ។

៦.បន្ទាប់ពីមូអាវីយ៉ាស្ទ៍ ខ៊ីលីហ្វាស្ទ៍ត្រឡប់មកអល់-ហាសាន់ صلوات الله عليه والسلام វិញ ។ បើអាល់-ហាសាន់ صلوات الله عليه والسلام ចូលទិវង្គតខ៊ីលីហ្វាស្ទ៍បានទៅអាល់-ហ៊ុសៃន៍ صلوات الله عليه والسلام ។

ទិសទីគំរាមនោះ ជាជាងជ្រើសយករឿងផ្សេងៗទៀត ទោះជាជ្រើសយករឿងផ្សេងៗឯទៀតនោះជាទង្វើស្របច្បាប់អល់ឡោះហ៊ូ عز وجل ដែរក៏ដោយ ។

ដូចព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام បានធ្វើដែរ កាលព្រះសាស្ដា صلى الله عليه وآله وسلم ចូលទិវង្គតនោះ អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ព្រមធ្វើសន្ធិសញ្ញាសន្តិភាពជាមួយមូអាវីយ៉ាស់ ដោយដាក់លក្ខខណ្ឌនានាដើម្បីរក្សាផលប្រយោជន៍សហគមន៍មុស្លីមនិងស្ថានភាពដំហរអោស្វលុលបៃត៍ عليهم السلام ។

## សន្តិភាព

ស្នៀតយុទ្ធសាស្ត្ររបស់មូអាវីយ៉ាស់ គឺធ្វើឲ្យអ៊ីម៉ាំ صلوات الله عليه والسلام លែងមានពាក្យសំអាងដើម្បីបន្តការតស៊ូនិងការកាន់ខ៊ិលីហ្វាស់តទៀត ។ លុះមូអាវីយ៉ាស់ឃើញថាអ៊ីម៉ាំ صلوات الله عليه والسلام គិតលាលែងតំណែង ហើយឃើញថាបញ្ហាតែមួយដែលត្រូវដោះស្រាយនោះគឺលក្ខខណ្ឌនានា និងការធានារ៉ាប់រងដែលត្រូវឲ្យទៅព្រះអង្គ صلوات الله عليه والسلام មូអាវីយ៉ាស់ក៏បានផ្ញើក្រដាសសមួយសន្លឹកទៅអ៊ីម៉ាំ صلوات الله عليه والسلام ដោយមានចុះហត្ថលេខានិងបោះត្រានៅលើក្រដាសនោះជាស្រេច សូមឲ្យអ៊ីម៉ាំ صلوات الله عليه والسلام សរសេរលក្ខខណ្ឌទាំងអស់ដែលព្រះអង្គ صلوات الله عليه والسلام ចង់បាននោះ នៅ



ព្រះរាជទានឲ្យគាត់នូវថវិកាមួយចំនួនធំ ។ អ៊ីម៉ាំ صلوات الله عليه والسلام ក៏បានទៅផ្ទះបុរសនោះ ហើយបានប្រាក់ឲ្យទៅគាត់តាមចំនួនដែលគាត់បានសូមអល់ឡោះហ៊ូ عز وجل ។

## អ៊ីម៉ាំ صلوات الله عليه والسلام និងអំណាច

ក្រោយឃាតកម្មរបស់អ៊ីម៉ាំអ៊ាលីឌ៊ុជ ថ្ងៃទី ២១ ខែរ៉ម៉ាដូន ឆ្នាំ ៤០ សករាជហ៊ិច្ជរ៉ោះត៍ អាល់-ហាសាន់ صلوات الله عليه والسلام ព្រះរាជបុត្រ صلوات الله عليه والسلام ច្បងរបស់ព្រះអង្គ صلوات الله عليه والسلام បានឡើងកាន់ខ៊ិលីហ្វាស់ជួសព្រះអង្គ صلوات الله عليه والسلام ។ មុស្លីមបានសច្ចាស្មោះស្ម័គ្រចំពោះព្រះអង្គ صلوات الله عليه والسلام ។ កាលនោះអ៊ីម៉ាំ صلوات الله عليه والسلام មានព្រះជន្ម ៣៧ វស្សា ។

ចាប់តាំងពីថ្ងៃដំបូងម្ល៉េះ ដែលព្រះអង្គ صلوات الله عليه والسلام បានឡើងកាន់អំណាច ព្រះអង្គ صلوات الله عليه والسلام បានធ្វើសុន្ទរកថាមួយ ដែលល្បីនៅក្នុងប្រវត្តិសាស្ត្រ ថាព្រះអង្គ صلوات الله عليه والسلام នឹងអនុវត្តិតាមគន្លងនយោបាយព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام ហើយព្រះអង្គ صلوات الله عليه والسلام នឹងកម្ទេចឯកសិទ្ធិអយុត្តិធម៌ ដូចតទៅ៖ «យប់នេះបុរសម្នាក់បានស្លាប់ ។ បុគ្គលមុនៗមិនដែលបានប្រព្រឹត្តអំពើល្អលើសព្រះអង្គ صلوات الله عليه والسلام ទេ ចំណែកឯបុគ្គលក្រោយៗ ក៏មិនបានឈានទៅដល់លំដាប់ថ្នាក់ព្រះអង្គ صلوات الله عليه والسلام

ទេដែរ ! ព្រះអង្គ صلوات الله عليه والسلام បានប្រយុទ្ធក្បែរព្រះសាស្ដា صلى الله عليه وآله وسلم ដោយការពារព្រះអង្គ صلى الله عليه وآله وسلم ។ ព្រះសាស្ដា صلى الله عليه وآله وسلم អល់ឡោះហ៊ូ عزوجل បានប្រគល់ទង់របស់ព្រះអង្គ صلى الله عليه وآله وسلم ឲ្យទៅព្រះអង្គ صلوات الله عليه والسلام កាន់ ។ ទេវតាពីរអង្គ عليهم السلام យ៉ីបរ៉អ៊ីល عليه السلام និងមីកាអ៊ីល عليه السلام បាននៅខាងព្រះអង្គ صلوات الله عليه والسلام លុះត្រាតែព្រះអង្គ صلوات الله عليه والسلام បានទទួលជ័យជំនះសមរភូមិទើបព្រះអង្គ صلوات الله عليه والسلام ត្រឡប់មកវិញ ! ព្រះអង្គ صلوات الله عليه والسلام ចូលទិវង្គតក្នុងយប់តែមួយដែលអ៊ីសា عليه السلام បានឡើងទៅឯព្រះម្ចាស់ عزوجل ព្រះអង្គ عليه السلام យប់តែមួយដែលយូស្ស៊ីអ៊ា عليه السلام ព្រះរាជបុត្រ عليه السلام របស់នូន عليه السلام អ្នកស្នងមូសា عليه السلام បានចូលទិវង្គត ។ ព្រះអង្គ صلوات الله عليه والسلام មិនបានបន្សល់ទុកនូវពណ៌សនិងពណ៌លឿងទេលើកលែងតែប្រាក់ ៧០០ ឌៀរហ៊ាំដែលព្រះអង្គ صلوات الله عليه والسلام មានបំណងរកស្រីបម្រើឲ្យព្រះមហេសី سلام الله عليها ព្រះអង្គ صلوات الله عليه والسلام ។» អ៊ីម៉ាំ صلوات الله عليه والسلام ហូរទឹកភ្នែក ។ អ្នកឯទៀតបានយំជាមួយព្រះអង្គ صلوات الله عليه والسلام ។ បន្ទាប់មក ព្រះអង្គ صلوات الله عليه والسلام មានវចនៈថាៈ

«ខ្ញុំ صلوات الله عليه والسلام ជាកូនរបស់បុគ្គល صلوات الله عليه والسلام ដែលបាននាំមកឲ្យអស់លោកនូវប្រផ្នូលល្អ ។ ខ្ញុំ صلوات الله عليه والسلام ជាកូនរបស់បុគ្គល صلوات الله عليه والسلام ដែលបានដាស់តឿនអស់លោក ។ ខ្ញុំ صلوات الله عليه والسلام ជាកូនរបស់បុគ្គល صلوات الله عليه والسلام ដែលបានហៅអស់លោកមករកអល់ឡោះហ៊ូ عزوجل តាមព្រះបញ្ជាព្រះអង្គ عزوجل ។ ខ្ញុំ صلوات الله عليه والسلام ជាកូនរបស់ចន្លុះភ្លឺរន្ទាល ។ ខ្ញុំ صلوات الله عليه والسلام មកពីគ្រួសារដែលអល់ឡោះហ៊ូ عزوجل ជម្រះបន្សុទ្ធ ដែលអល់ឡោះហ៊ូ عزوجل បាន





ជាមួយពួកសត្រូវ ។ បន្ទាប់ពីនោះ ហេ់ពលទាំងអស់របស់ព្រះអង្គ صلوات الله عليه والسلام ដែលនៅសល់នោះនឹងសាបសូន្យ ហើយប្រាកដជានឹងត្រូវកាប់សម្លាប់ដោយពួកទាហានស៊ីឈ្នួលរបស់មូអ៊ាវីយ៉ាស្ស៊ជាមិនខាន ។ មានតែសាវកភក្ដីរបស់ព្រះអង្គ صلوات الله عليه والسلام ទេដែលស្គាល់អ៊ីស្លាមត្រឹមត្រូវ ។ ប្រសិនបើសាវកភក្ដីរបស់ព្រះអង្គ صلوات الله عليه والسلام ស្លាប់អស់នោះ អំណាចនឹងធ្លាក់ទៅក្នុងកណ្ដាប់ដៃពួកអ៊ូម៉ៃយ៉ាស្ស៊ ចំណែកឯសាសនាអ៊ីស្លាមទាំងមូលនឹងខូចនិងត្រូវកាឡៃបំភ្លៃ ។

-ជម្រើសទីពីរ គឺលាលែងពីតំណែងដោយដាក់លក្ខខណ្ឌតឹងរ៉ឹងដើម្បីរក្សាការពារសាសនាអ៊ីស្លាម ។

តើគេអាចគិតបានទេថាអ៊ីម៉ាំ صلوات الله عليه والسلام ដែលជាបុគ្គលថ្លៃថ្នូរនិងជាសទ្ធាធិមុត្តនោះ នឹងបន្តការធ្វើសង្គ្រាមក្នុងសភាពបែបនេះ? ទេ ព្រះអង្គ صلوات الله عليه والسلام មិនអាចធ្វើបែបនេះបានទេ ពីព្រោះនេះមិនគ្រាន់តែជាការគេចបញ្ហានោះទេ ថែមទាំងជាការឃើញតែប្រយោជន៍ផ្ទាល់ខ្លួនទៀតផង ។ អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ដែលជាបុគ្គលសុក្រឹតឥតខ្ចោះ មិនមែនបុគ្គលដែលឃើញតែប្រយោជន៍ផ្ទាល់ខ្លួននោះទេ ។

ជាថ្មីម្ដងទៀត ព្រះអង្គ صلوات الله عليه والسلام បានជ្រើសយកសេចក្ដីស្រឡាញ់អល់ឡោះហ៍ عز وجل និងស្មារតីទទួលខុសត្រូវចំពោះសហគមន៍មុស្លីម ដែលត្រូវសត្រូវគ្រប់



បញ្ចៀសឆ្ងាយពីមន្ទិល ។ ខ្ញុំ صلوات الله عليه والسلام មកពីគ្រួសារដែលអល់ឡោះហ៍ عز وجل ថារមិត្តភាពនៅក្នុងព្រះគម្ពីរព្រះអង្គ عز وجل ថា៖ « ចូរអ្នកថា៖ "ខ្ញុំមិនសូមឈ្នួលពីអស់លោកទេ ខ្ញុំសូមឲ្យតែអស់លោកអាណិតស្រឡាញ់បណ្ដាសាច់សាលោហិតជំនិតរបស់ខ្ញុំប៉ុណ្ណោះ ។" អ្នកណាប្រព្រឹត្តអំពើល្អ យើងនឹងថែមឲ្យអ្នកនោះនូវអ្វីដែលល្អក្នុងអំពើល្អនោះ (ស៊ូ.42 អា.23) ។» ការសាងអំពើល្អជាមិត្តភាពរបស់យើង អាស្ហុលុល-បៃត៍ عليهم السلام ។" ដល់ត្រង់នេះ អ៊ាប់ឌុលឡោះហ៍ អ៊ីបនូ អ៊ាប់បាស់ សាវកព្រះសាស្ដា صلى الله عليه وآله وسلم បានក្រោកឡើង ហើយបានថា៖ "នេះគឺរាជបុត្រ صلوات الله عليه والسلام របស់ព្រះសាស្ដា صلى الله عليه وآله وسلم របស់អស់លោក ជាអាណាព្យាបាល ដែលត្រូវជ្រើសរើសដោយអ៊ីម៉ាំ صلوات الله عليه والسلام របស់អស់លោក ។ ចូរអស់លោកសច្ចាស្មោះស្ម័គ្រ និងមានភក្ដីភាពចំពោះព្រះអង្គ صلوات الله عليه والسلام ទៅ ។" មនុស្សទាំងឡាយបានព្រមធ្វើតាមការស្នើសូមរបស់អ៊ីបនូ អ៊ាប់បាស់ ហើយបានថា៖ "ព្រះអង្គគួរឲ្យស្រឡាញ់មែន! ហើយចាំបាច់ត្រូវមានភក្ដីភាពចំពោះព្រះអង្គ!" ពួកគេរាល់គ្នាបានចូលមកធ្វើកិច្ចសច្ចាប្រណិធាន (بَيْعَة) ជាបន្តបន្ទាប់គ្នា ។

អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ត្រូវបានតែងតាំង ជាខ៊ុលិហ្វរបស់មុស្លីមទាំងឡាយដូច្នេះឯង ។

# មូអ៊ាវីយ៉ាស្ទ់រៀបផែនការក្បត់

កាលពីមុនមូអុាវីយ៉ាស្ទ់បានប្រឆាំងអុីមុាំអុាលី صلوات الله عليه والسلام ។ ពេលនេះមូអុាវីយ៉ាស្ទ់នៅតែប្រឆាំងអ្នកស្នងព្រះអង្គ صلوات الله عليه والسلام អុីមុាំអាល់-ហ្សាសាន់ صلوات الله عليه والسلام ជាបន្ត ។ លុះដំណឹងសច្ចាប្រណិធានបានលេចឮទៅដល់ដ្វាម៉ាស់ មូអុាវីយ៉ាស្ទ់បានចាត់បញ្ជូនចារបុរសមកយ៉ាងច្រើន និងបានចាត់បញ្ជូនបេសកជនទៅរកសម្ព័ន្ធមិត្តទាំងឡាយរបស់អុីមុាំ صلوات الله عليه والسلام ដោយផ្តាំឲ្យបេសកជនទាំងនេះបង្កអន្តរាយនិងធ្វើឲ្យស្ថានភាពក្នុងរដ្ឋធានីអុីស្លាម នគរគូហ្វាស្ទ់ កាន់តែដុនដាបខ្លាំង ។

អុីមុាំអាល់-ហ្សាសាន់ صلوات الله عليه والسلام ដឹងច្បាស់អំពីផែនការរបស់មូអុាវីយ៉ាស្ទ់ ។ ព្រះអង្គ صلوات الله عليه والسلام បានបញ្ជាឲ្យប្រហារជីវិតចារបុរសទាំងអស់ ដែលត្រូវចាប់ខ្លួនបាន បានផ្ញើសំបុត្រមួយច្បាប់ទៅបុគ្គលបះបោរនៅដ្វាម៉ាស់ថា៖ "អ្នកឯងបានឲ្យគេលបចូលក្នុងលំនៅយើង ហាក់ដូចជាអ្នកឯងចង់ជួបយើង ។ ដូច្នេះអ្នកឯងនឹងបានជួបយើង ។ ចូររង់ចាំទៅ តាមព្រះបំណងអល់ឡោះហ៍ عز وجل !"





មានមេដឹកនាំជាអ្នកស្រឡាញ់ជីវិតនិងជាអ្នកសម្ភារនិយម ។ ដូច្នេះ មូអាវីយ៉ាស្ទ័ងាយស្រួលក្នុងការទិញពួកមេដឹកនាំទាំងនេះ ដោយឲ្យទ្រព្យយ៉ាងច្រើនទៅពួកនេះ ។ តែការពិតស្ថានភាពដុនដាបខ្លាំងលើសនេះទៅទៀត ។ មូអាវីយ៉ាស្ទ័អាចសូកប៉ាន់មេបញ្ជាការរបស់ទ័ពនេះបាន គឺ អ៊ូបៃឌុល្លទ្បោះហ៊្ មុីបនូអាប់បាស់ ដែលត្រូវជាបងប្អូនជីដូនមួយរបស់អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ។

នៅពេលដែលពួកមេកងពលបានចាកចេញអស់ ជាបន្តបន្ទាប់ក្នុងពេលយប់ មេបញ្ជាការរបស់ពួកគេបានទៅចូលជាមួយពួកសត្រូវ ដូរនឹងប្រាក់មួយលានឌៀរហ៊ាំ ។

អំពើក្បត់បានកើតឡើងជាបន្តបន្ទាប់ ។ សាវកក្លែងក្លាយម្នាក់របស់អ៊ីម៉ាំ صلوات الله عليه والسلام បានប៉ងសម្លាប់ព្រះអង្គ صلوات الله عليه والسلام ។ ព្រះអង្គ صلوات الله عليه والسلام បានរងរបួសធ្ងន់ត្រង់ជើង ។

ក្នុងចន្លោះពេលនោះ មូអាវីយ៉ាស្ទ័បានស្នើធ្វើសន្ធិសញ្ញាសន្តិភាពសាជាថ្មីដោយដាក់លក្ខខណ្ឌ ឲ្យអ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام លាលែងពីតំណែងខលីហ្វាស្ទ័ ។ អ៊ីម៉ាំ صلوات الله عليه والسلام មានជម្រើសលំបាកពីរគឺ៖

-ជម្រើសទីមួយ គឺធ្វើសង្គ្រាមនិងមិនលាលែងពីតំណែងទេ ។ បានសេចក្តីថារហ័ពលកាតច្រើនរបស់ព្រះអង្គ صلوات الله عليه والسلام នឹងរត់ចោលទ័ពខ្លួន ទៅចូល



# ការប្រុងប្រៀបធ្វើសង្គ្រាម

មូអាវីយ៉ាស្ទ័ បុគ្គលបះបោរ បានបញ្ជាឲ្យទ័ពរបស់ខ្លួនចូលលុកលុយដើម្បីបំភ័យពួកមុស្លីម និងធ្វើឲ្យស្ថានការណ៍អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ជ្រួលច្របល់ ។ ការប្រយុទ្ធរបស់មូអាវីយ៉ាស្ទ័បានប្រព្រឹត្តទៅដោយមានការប្លន់និងការកាប់សម្លាប់ដែលពួកមុស្លីមមិនធ្លាប់ប្រទះ ។

ចន្លោះពេលនោះ អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام បានកែនទ័ពនិងត្រៀមខ្លួនប្រយុទ្ធផ្តាច់ព្រ័ត្រ ។ ដើម្បីធ្វើឲ្យមនុស្សប្រុងខ្លួនចំពោះទុក្ខវេទនានេះ ព្រះអង្គ صلوات الله عليه والسلام បានប្រកាសប្រាប់ពួកគេថា៖ “អល់ឡោះហ៊្ عز وجل បានបញ្ជាឲ្យប្រយុទ្ធនឹងពួកបដិសេធសទ្ធា ហើយបានហៅការប្រយុទ្ធនេះថា «ការបង្ខិតបង្ខំ» យុទ្ធជនអើយ ! ចូរស្ងប់ ។ ពិតណាស់ អល់ឡោះហ៊្ عز وجل នៅជាប់ជាមួយអ្នកស្ងប់ ។ អស់លោកនឹងមិនទទួលបានអ្វីឡើយបើគ្មានអំណត់ និងគ្មានសេចក្តីស្ងប់ចំពោះការបង្ខិតបង្ខំទេនោះ ! សូមឲ្យព្រះមេត្តាប្រណីរបស់អល់ឡោះហ៊្ عز وجل កើតមានលើអស់លោក ។ ចូរចាកចេញទៅកាន់បន្ទាយនូខៃឡាស់ ។”

តែសកម្មភាពរបស់បុគ្គលបះបោរបានហុចលទ្ធផលឲ្យហើយ ។ បុគ្គលអន់សទ្ធាក្នុងបក្សអ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام បានលក់សាសនាខ្លួន ។ ចំណែកឯអ្នក





មានសទ្ធាមុតមាំបានបាក់ទឹកចិត្ត លែងជឿថានឹងមានជ័យជំនះ ។ មានការរួញរាក្នុងការឆ្លើយតបអ៊ីម៉ាំ ឯជំនួយក៏យឺតពេល ។ សាវកភ័ក្តីដ៏កម្រព្យាយាមស្តារស្ថានភាពឡើងវិញ ។ សាវកម្នាក់ឈ្មោះអ៊ាឌី អ៊ីបនូ ហ៊ាទិម (عدي ابن حاتم) ប្រាប់យុទ្ធជនរួញរាថា៖ “ខ្ញុំឈ្មោះអ៊ាឌី អ៊ីបនូ ហ៊ាទិម (عدي ابن حاتم) ។ សូមថ្វាយសេចក្តីបរិសុទ្ធចំពោះអល់ឡោះហ៍ឌ៊ុញ ។ អស់លោកស្ថិតនៅក្នុងស្ថានភាពគួរឲ្យស្អប់ខ្ពើមនិងដែលគួរធ្វើទោស ។ អស់លោកមិនឆ្លើយតបអ៊ីម៉ាំ صلوات الله عليه والسلام ព្រះរាជនត្តា صلوات الله عليه والسلام របស់ព្រះសាស្តា صلى الله عليه وآله وسلم ទេឬ? ឯណាទៅអ្នកមានវិហាររបស់អស់លោកដែលមានមាត់ដាចក្នុងការសន្ទនានិងក្នុងជម្លោះនោះ? តែលុះយកប្រាកដប្រជាអ្នកនោះគេចមុខបាត់ដូចសត្វកញ្ជ្រោង ។ អស់លោកមិនខ្លាចព្រះពិរោធអល់ឡោះហ៍ عز وجل ទេ?” និយាយចប់ហើយ អ៊ាឌី អ៊ីបនូ ហ៊ាទិម បានឡើងជិះសេះទៅកាន់បន្ទាយនូខៃឡាស់ ។ អ្នកគាំទ្រខ្លះក៏បានប្រមូលយុទ្ធជនដែរ ។ ការកែនពលបានប្រព្រឹត្តទៅទាំងត្រដាបត្រដួស ។ ទ័ពមួយដែលមានរហ់ពលមួយម៉ឺនពីរពាន់នាក់ក៏បានកកើតឡើង ។ មេបញ្ជាការរបស់ទ័ពនេះគឺអ៊ូបៃឌុលឡោះហ៍ អ៊ីបនូ អ៊ាប់បាស់ដែលបានបាត់បង់កូនប្រុសវ័យកុមារពីរនាក់កាលត្រូវទ័ពមូអាវីយ៉ាស្ទ់រាយលុកលុយ ។

ទ័ពអ៊ីម៉ាំ صلوات الله عليه والسلام មានចំណុចខ្សោយច្រើនគឺ៖ កុលសម្ព័ន្ធច្រើនរបស់ទ័ពនេះ